ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ..១៧៥០......សហវ....ប្រ.ឋាក.នាយក

# ប្រកាស
## ស្តីពី
## ពន្ធលើផ្ទាំងផ្សព្វផ្សាយ

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥២៣/០០៤ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៨៧ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីពន្ធលើផ្ទាំងផ្សព្វផ្សាយ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

# សម្រេច

**ប្រការ១ ._**

ប្រកាសនេះ មានគោលបំណងកំណត់នូវវិធាននិងនីតិវិធីនៃការគ្រប់គ្រងប្រមូលពន្ធលើផ្ទាំងផ្សព្វផ្សាយគ្រប់ប្រភេទ។

**ប្រការ២ ._**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះការផ្សព្វផ្សាយតាមគ្រប់រូបភាពទាំងចល័ត និងអចល័តនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៣ ._**

សម្រាប់គោលដៅនៃប្រកាសនេះ៖

១- ផ្ទាំងផ្សព្វផ្សាយ សំដៅដល់ បណ្ណ ស្លាក ឬផ្ទាំងដែលមានអក្សរ គំនូរ និង/ឬរូបភាពជីវចលឬអជីវចល សម្រាប់គោលបំណងផ្សព្វផ្សាយពាណិជ្ជកម្ម ដើម្បីឱ្យអតិថិជនឬសាធារណជនបានស្គាល់អំពីផលិតផល សេវាកម្ម និងព័ត៌មានផ្សេងទៀតពាក់ព័ន្ធនឹងអាជីវកម្មរបស់អ្នកជាប់ពន្ធ មានជាអាទិ៍៖

ក- បណ្ណប្រកាសផ្សាយពាណិជ្ជកម្មធ្វើអំពីក្រដាសធម្មតា ដែលមានអក្សរ គំនូរ និង/ឬរូបភាព ត្រូវបានបោះពុម្ពឬគូរ សម្រាប់ផ្សព្វផ្សាយពាណិជ្ជកម្ម។

ខ- បណ្ណប្រកាសផ្សាយពាណិជ្ជកម្មធ្វើអំពីកៅស៊ូ កំណាត់សំពត់ ឬវត្ថុផ្សេងៗ ដែលមានអក្សរ គំនូរ និង/ឬរូបភាព ត្រូវបានបោះពុម្ពឬគូរ ដែលមានផ្ទៃក្រឡាមិនលើសពី ១០០ដេស៊ីម៉ែត្រការ៉េ សម្រាប់ផ្សព្វផ្សាយក្នុងរយៈពេល ៩០ថ្ងៃ ឬតិចជាង។ បណ្ណប្រកាសផ្សាយពាណិជ្ជកម្មដែលមានផ្ទៃក្រឡាលើសពី ១០០ ដេស៊ីម៉ែត្រការ៉េ ឬផ្សព្វផ្សាយក្នុងរយៈពេលលើសពី ៩០ថ្ងៃ ត្រូវចាត់ទុកជាផ្ទាំងអក្សរ ឬផ្ទាំងរូបភាព សម្រាប់គោលបំណងផ្សាយពាណិជ្ជកម្ម។

គ- ស្លាកអាជីវកម្មដ្ឋាន សម្រាប់ដាក់សម្គាល់ឈ្មោះ ទីតាំង ទីស្នាក់ការ ការិយាល័យ ឬទីកន្លែងប្រកបអាជីវកម្មនានាដែលស្ថិតនៅពីមុខអគារ ឬដាក់ភ្ជាប់នឹងអគារ ឬច្រកចូលអគារឬខ្លោងទ្វារ។ សហគ្រាសឬអាជីវកម្មដ្ឋានមួយ ត្រូវមានស្លាកអាជីវកម្មដ្ឋានតែមួយប៉ុណ្ណោះ។ សាខាសហគ្រាសដែលបានចុះបញ្ជីនៅអគ្គនាយកដ្ឋានពន្ធដារ ត្រូវបានអនុញ្ញាតឱ្យមានស្លាកអាជីវកម្មដ្ឋានតែមួយរបស់សាខានោះដែលមានឈ្មោះដូចសហគ្រាសដើម។ ដោយឡែក ស្លាកផ្សេងទៀតរបស់សហគ្រាសដើមឬសាខា ត្រូវចាត់ទុកជាផ្ទាំងអក្សរ ឬផ្ទាំងរូបភាព សម្រាប់គោលបំណងផ្សាយពាណិជ្ជកម្ម។

ឃ- ផ្ទាំងអក្សរឬផ្ទាំងរូបភាពចល័ត សម្រាប់ផ្សព្វផ្សាយពាណិជ្ជកម្មដែលដាក់ភ្ជាប់ តភ្ជាប់ ឬគូរផ្ទាល់នឹងមធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទ ដូចជា រថយន្ត រថភ្លើង កប៉ាល់ រ៉ឺម៉ក ទោចក្រយានយន្ត ត្រីចក្រយានយន្តជាដើម។

ង- ផ្ទាំងអក្សរឬផ្ទាំងរូបភាពអចល័ត សម្រាប់ផ្សព្វផ្សាយពាណិជ្ជកម្មដែលស្ថិតនៅមួយកន្លែង រួមទាំងការបញ្ចាំងជាអក្សរ ឬរូបភាពតាមរយៈអេក្រង់ទូរទស្សន៍ ឬអេក្រង់ អិល.អ៊ី.ឌី ឬឧបករណ៍ឬអេក្រង់ផ្សព្វផ្សាយផ្សេងៗ។

ច- ស្លាកឬផ្ទាំងផ្សព្វផ្សាយដូចមានចែងក្នុងវាក្យខណ្ឌ គ វាក្យខណ្ឌ ឃ និងវាក្យខណ្ឌ ង នៃកថាខណ្ឌនេះ កំណត់ថាជាស្លាកឬផ្ទាំងមានពន្លឺ ក្នុងករណីដែលស្លាកឬផ្ទាំងផ្សព្វផ្សាយនោះមានបំពាក់ពន្លឺពីក្នុង ឬពីក្រៅ។

២- អ្នកជាប់ពន្ធ សំដៅដល់ រូបវន្តបុគ្គលឬនីតិបុគ្គលដែលធ្វើការផ្សព្វផ្សាយដោយខ្លួនឯង ឬជួលគេឱ្យធ្វើការផ្សព្វផ្សាយ ឬត្រូវបានគេជួលឱ្យធ្វើការផ្សព្វផ្សាយនូវផ្ទាំងផ្សព្វផ្សាយដូចមានចែងក្នុងកថាខណ្ឌទី១ នៃប្រការនេះ។

**ប្រការ៤ ._**

១- ផ្ទាំងផ្សព្វផ្សាយដូចមានចែងក្នុងប្រការ៣ នៃប្រកាសនេះ ត្រូវជាប់ពន្ធលើផ្ទាំងផ្សព្វផ្សាយទៅតាមប្រភេទ អត្រា និងលក្ខខណ្ឌបន្ថែម ដូចក្នុងតារាងខាងក្រោម៖



k-

| លេខរៀង | ប្រភេទផ្ទាំងផ្សព្វផ្សាយ | អត្រាពន្ធ | | លក្ខខណ្ឌបន្ថែម |
|---|---|---|---|---|
| ១- បណ្ណប្រកាសផ្សាយពាណិជ្ជកម្មធ្វើអំពីក្រដាសធម្មតា ដូចមានចែងក្នុងវាក្យខណ្ឌ ក នៃកថាខណ្ឌទី១ នៃប្រការ៣ នៃប្រកាសនេះ: | | | | |
| ក | មានផ្ទៃក្រឡាមិនលើសពី ៤០ដេស៊ីម៉ែត្រការ៉េ | ៥០០៛/ទំព័រ | | បើមានអក្សរបរទេស ១ ៥០០៛/ទំព័រ |
| ខ | មានផ្ទៃក្រឡាលើសពី ៤០ដេស៊ីម៉ែត្រការ៉េ | ៧០០៛/ទំព័រ | | បើមានអក្សរបរទេស ២ ១០០៛/ទំព័រ |
| ២- បណ្ណប្រកាសផ្សាយពាណិជ្ជកម្មធ្វើអំពីកៅស៊ូ កំណាត់សំពត់ ឬវត្ថុផ្សេងៗ ដូចមានចែងក្នុងវាក្យខណ្ឌ ខ នៃកថាខណ្ឌទី១ នៃប្រការ៣ នៃប្រកាសនេះ: | | | | |
| ក | មានផ្ទៃក្រឡាមិនលើសពី ៤០ដេស៊ីម៉ែត្រការ៉េ | ៧០០៛/ផ្ទាំង | | បើមានអក្សរបរទេស ២ ១០០៛/ផ្ទាំង |
| ខ | មានផ្ទៃក្រឡាលើសពី ៤០ ដល់ ១០០ដេស៊ីម៉ែត្រការ៉េ "បើលើសពី ១០០ដេស៊ីម៉ែត្រការ៉េ គិតជាផ្ទាំងអក្សរឬផ្ទាំងរូបភាព" | ១ ០០០៛/ផ្ទាំង | | បើមានអក្សរបរទេស ៣ ០០០៛/ផ្ទាំង |
| ៣- ស្លាកអាជីវកម្មដ្ឋាន ដូចមានចែងក្នុងវាក្យខណ្ឌ គ នៃកថាខណ្ឌទី១ នៃប្រការ៣ នៃប្រកាសនេះ: | | | | |
| ក | គ្មានពន្លឺលើកស្របដងផ្លូវ | ១០០៛/ជម២/ឆ្នាំ | ២០០៛ | បើមានអក្សរបរទេសត្រូវគិតបន្ថែមក្នុងអក្សរមួយតួ និងក្នុងកម្ពស់មួយដេស៊ីម៉ែត្រ ឬប្រភាគ |
| ខ | គ្មានពន្លឺកែងដងផ្លូវ | ១៥០៛/ជម២/ឆ្នាំ | ៣០០៛ | |
| ៤- ស្លាកអាជីវកម្មដ្ឋាន ដូចមានចែងក្នុងវាក្យខណ្ឌ គ និងវាក្យខណ្ឌ ច នៃកថាខណ្ឌទី១ នៃប្រការ៣ នៃប្រកាសនេះ: | | | | |
| ក | មានពន្លឺលើកស្របដងផ្លូវ | ២០០៛/ជម២/ឆ្នាំ | ៤០០៛ | បើមានអក្សរបរទេសត្រូវគិតបន្ថែមក្នុងអក្សរមួយតួ និងក្នុងកម្ពស់មួយដេស៊ីម៉ែត្រ ឬប្រភាគ |
| ខ | មានពន្លឺកែងដងផ្លូវ | ២៥០៛/ជម២/ឆ្នាំ | ៥០០៛ | |
| ៥- ផ្ទាំងអក្សរឬផ្ទាំងរូបភាព ដូចមានចែងក្នុងវាក្យខណ្ឌ ង នៃកថាខណ្ឌទី១ នៃប្រការ៣ នៃប្រកាសនេះ: | | | | |
| ក | គ្មានពន្លឺលើកស្របដងផ្លូវ | ៥០០៛/ជម២/ឆ្នាំ | ១ ០០០៛ | បើមានអក្សរបរទេសត្រូវគិតបន្ថែមក្នុងអក្សរមួយតួ និងក្នុងកម្ពស់មួយដេស៊ីម៉ែត្រ ឬប្រភាគ |
| ខ | គ្មានពន្លឺកែងដងផ្លូវ | ៧០០៛/ជម២/ឆ្នាំ | ១ ៤០០៛ | |
| ៦- ផ្ទាំងអក្សរឬផ្ទាំងរូបភាព ដូចមានចែងក្នុងវាក្យខណ្ឌ ង និងវាក្យខណ្ឌ ច នៃកថាខណ្ឌទី១ នៃប្រការ៣ នៃប្រកាសនេះ: | | | | |
| ក | មានពន្លឺលើកស្របដងផ្លូវ | ៧០០៛/ជម២/ឆ្នាំ | ១ ៤០០៛ | បើមានអក្សរបរទេសត្រូវគិតបន្ថែមក្នុងអក្សរមួយតួ និងក្នុងកម្ពស់មួយដេស៊ីម៉ែត្រ ឬប្រភាគ |
| ខ | មានពន្លឺកែងដងផ្លូវ | ១ ០០០៛/ជម២/ឆ្នាំ | ២ ០០០៛ | |
| ៧- ផ្ទាំងអក្សរឬផ្ទាំងរូបភាព ដូចមានចែងក្នុងវាក្យខណ្ឌ ឃ នៃកថាខណ្ឌទី១ នៃប្រការ៣ នៃប្រកាសនេះ: | | | | |
| ក | ដាក់ភ្ជាប់ តភ្ជាប់ ឬគូរផ្ទាល់នឹងមធ្យោបាយដឹកជញ្ជូននានា | ១ ៥០០៛/ជម២/ឆ្នាំ | ៣ ០០០៛ | បើមានអក្សរបរទេសត្រូវគិតបន្ថែមក្នុងអក្សរមួយតួ និងក្នុងកម្ពស់មួយដេស៊ីម៉ែត្រ ឬប្រភាគ |

២- ក្នុងករណីស្លាកអាជីវកម្មដ្ឋានឬផ្ទាំងអក្សរឬរូបភាព មានភ្ជាប់ផ្ទាំងផ្សព្វផ្សាយរបស់សហគ្រាសឬអាជីវកម្មដ្ឋានផ្សេង ការគណនាប្រាក់ពន្ធត្រូវធ្វើឡើងតាមប្រភេទ អត្រា និងលក្ខខណ្ឌបន្ថែម ដូចមានចែងក្នុងកថាខណ្ឌទី១ នៃប្រការនេះ ទៅតាមផ្ទៃក្រឡាដែលជាចំណែកផ្ទាល់របស់សហគ្រាសឬអាជីវកម្មដ្ឋាននោះ។

៣- ចំពោះនិមិត្តសញ្ញា (ឡូហ្គោ) អាសយដ្ឋាន លេខទូរស័ព្ទ និងគេហទំព័រ ដែលមានអក្សរបរទេសនៅក្នុងផ្ទាំងផ្សព្វផ្សាយ មិនត្រូវរាប់បញ្ចូលក្នុងលក្ខខណ្ឌបន្ថែម ដូចមានចែងក្នុងកថាខណ្ឌទី១ នៃប្រការនេះ។

**ប្រការ៥ .-**

ពន្ធលើផ្ទាំងផ្សព្វផ្សាយ ត្រូវបានលើកលែងដូចខាងក្រោម៖

១- ស្លាករបស់ស្ថាប័នរដ្ឋ។

២- ស្លាករបស់ស្ថានទូតឬស្ថានកុងស៊ុលបរទេស អង្គការជាតិនិងអង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលដទៃទៀត អង្គការមិនមែនរដ្ឋាភិបាល និងសមាគមនានា។

៣- ផ្ទាំងផ្សព្វផ្សាយដែលមានគោលដៅអប់រំសង្គមជាប្រយោជន៍សាធារណៈ មានជាអាទិ៍ ការថែរក្សានិងការពារបរិស្ថាន ការបញ្ឈប់អំពើហិង្សាក្នុងគ្រួសារ ការការពារធនធានធម្មជាតិ ការអប់រំចរាចរណ៍ និងការអប់រំសុខភាព។

**ប្រការ៦ .-**

ការដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធ ត្រូវបានកំណត់ដូចខាងក្រោម៖

១- ចំពោះអ្នកជាប់ពន្ធដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ និងសាខាពន្ធដារខណ្ឌ ត្រូវដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធនៅទីចាត់ការពន្ធដាររាជធានីភ្នំពេញនៃអគ្គនាយកដ្ឋានពន្ធដារ។

២- ចំពោះអ្នកជាប់ពន្ធដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់សាខាពន្ធដារខេត្ត ត្រូវដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធនៅសាខាពន្ធដារខេត្តដែលគ្រប់គ្រងអ្នកជាប់ពន្ធ។

៣- ចំពោះបណ្ណប្រកាសផ្សាយពាណិជ្ជកម្មដែលធ្វើអំពីកៅស៊ូ ក្រដាសធម្មតា កំណាត់សំពត់ ឬវត្ថុផ្សេងៗ អ្នកជាប់ពន្ធត្រូវដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធឱ្យបានស្រេចបាច់ មុនធ្វើការផ្សព្វផ្សាយពាណិជ្ជកម្ម។

៤- ចំពោះស្លាកអាជីវកម្មដ្ឋាន និងផ្ទាំងអក្សរឬផ្ទាំងរូបភាពសម្រាប់គោលបំណងពាណិជ្ជកម្ម អ្នកជាប់ពន្ធត្រូវដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធ ក្នុងអំឡុងពេលចាប់ពីថ្ងៃទី១ ខែមករា ដល់ថ្ងៃទី៣១ ខែមីនា ជារៀងរាល់ឆ្នាំ។

៥- ចំពោះស្លាកអាជីវកម្មដ្ឋាន និងផ្ទាំងអក្សរឬផ្ទាំងរូបភាពសម្រាប់គោលបំណងពាណិជ្ជកម្ម ដែលផលិតថ្មី អ្នកជាប់ពន្ធត្រូវដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធឱ្យបានស្រេចបាច់ មុនធ្វើការផ្សព្វផ្សាយពាណិជ្ជកម្ម។

៦- ចំពោះស្លាកអាជីវកម្មដ្ឋាន និងផ្ទាំងអក្សរឬផ្ទាំងរូបភាពសម្រាប់គោលបំណងពាណិជ្ជកម្ម ដែលផលិតថ្មីរយៈពេល ៦ខែចុងឆ្នាំសារពើពន្ធ អ្នកជាប់ពន្ធត្រូវបង់ប្រាក់ពន្ធ ៥០ (ហាសិប) ភាគរយ នៃប្រាក់ពន្ធត្រូវបង់ ហើយត្រូវដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធឱ្យបានស្រេចបាច់ មុនធ្វើការផ្សព្វផ្សាយពាណិជ្ជកម្ម។

៧- អ្នកជាប់ពន្ធដែលធ្វើការផ្សព្វផ្សាយដោយខ្លួនឯងឬជួលគេឱ្យធ្វើការផ្សព្វផ្សាយត្រូវមានកាតព្វកិច្ចដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធលើផ្ទាំងផ្សព្វផ្សាយ។

៨- អ្នកជាប់ពន្ធណាមួយដែលត្រូវបានគេជួលឱ្យធ្វើការផ្សព្វផ្សាយ អ្នកជាប់ពន្ធនោះត្រូវទទួលខុសត្រូវក្នុងការដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធ ប្រសិនបើផ្ទាំងផ្សព្វផ្សាយមិនបានបង់ពន្ធលើផ្ទាំងផ្សព្វផ្សាយ។

**ប្រការ៧ .-**

ក្នុងករណីអ្នកជាប់ពន្ធមិនបានបំពេញកាតព្វកិច្ចដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធ ដូចមានចែងក្នុងប្រការ៦ នៃប្រកាសនេះ ក្រសួង ស្ថាប័នមានសមត្ថកិច្ច រួមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (រាជធានី/ខេត្ត ឬក្រុង/ស្រុក/ខណ្ឌ ឬឃុំ/សង្កាត់) មិនត្រូវចេញលិខិតអនុញ្ញាតទាក់ទិននឹងផ្ទាំងផ្សព្វផ្សាយ ហើយត្រូវជំរុញនិងបញ្ជូនរាល់ករណីស្នើសុំលើកស្លាកអាជីវកម្មដ្ឋាន និង/ឬផ្ទាំងអក្សរឬរូបភាពសម្រាប់គោលបំណងពាណិជ្ជកម្មនោះ មកបង់ប្រាក់ពន្ធជាមុនសិន។



Ա

**ប្រការ៨ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៩ .-**

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋាន ឬអគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ១១កើត ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី-ខេត្ត
- ដូចប្រការ៩ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ